**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ សុក្រ ៤ កើត ខែ ភទ្របទ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ពិធីដាក់ដំណើរការសាកល្បងនូវប្រព័ន្ធកំណត់អត្តសញ្ញាណសហគ្រាស (e-KYB)

នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០២៤, **ឯកឧត្តមបណ្ឌិត តាំង ខូនលី នាយកប្រតិបត្តិមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ"** ជាមួយនឹងតំណាងនៃក្រសួង ស្ថាប័នគោលចំនួន ៣ គឺ ក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រកាសដាក់ដំណើរការសាកល្បងនូវប្រព័ន្ធកំណត់អត្តសញ្ញាណសហគ្រាស (e-KYB) នៅមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" ដោយមានការចូលរួមពីសមាជិកដោយការស្នើសុំរបស់ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX) ផងដែរ។ ជាក់ស្តែង ប្រព័ន្ធ e-KYB គឺជាប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណ, ស្ថានភាព, អនុលោមភាពច្បាប់របស់ក្រុមហ៊ុន សហគ្រាស ភាពពាក់ព័ន្ធនឹងបុគ្គល ឬ ក្រុមហ៊ុន សហគ្រាសដទៃ និង គ្របដណ្តប់ដល់ការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីពន្ធដារ និង ការស្នើសុំសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស។ នាពេលកន្លងទៅ, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា បានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងលើការងារអភិវឌ្ឍប្រព័ន្ធ e-KYB នេះ នៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃថ្នាល CamDX ដើម្បីលើកទឹកចិត្ត និង បើកផ្លូវឱ្យក្រសួង ស្ថាប័នដទៃដែលមានទិន្នន័យគោលពាក់ព័ន្ធ ចូលរួមចែករំលែកមកក្នុងថ្នាល CamDX សម្រាប់គាំទ្រដល់ប្រព័ន្ធ e-KYB បន្ថែមទៀត សំដៅធ្វើឱ្យការងារកំណត់អត្តសញ្ញាណសហគ្រាសឌីជីថល កាន់តែមានភាពសុក្រឹត្យ។

ជាឧត្តមានុវត្តន៍ជាតិថ្មី, ប្រព័ន្ធ e-KYB មានលក្ខណៈស្រដៀងទៅនឹងប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល (Electronic Known Your Customer ឬ e-KYC) ដែលវិស័យឯកជនបាន និង កំពុងប្រើប្រាស់កន្លងមក, ពោលប្រព័ន្ធ e-KYB នឹងអនុញ្ញាតឱ្យមានការផ្ទៀងផ្ទាត់ជាពិន្ទុ (Scoring Verification) អនុលោមភាពលើទិន្នន័យដែលមានស្រាប់ របស់ក្រុមហ៊ុន សហគ្រាស។ ប្រព័ន្ធ e-KYB នឹងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់វិស័យសាធារណៈ ជាពិសេសប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងទៀតនៃរាជរដ្ឋាភិបាល ដូចជា ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិក (E-invoicing), ប្រព័ន្ធលទ្ធកម្មសាធារណៈ, ប្រព័ន្ធដាក់ពិន្ទុឥណទានទៅលើសហគ្រាស ជាដើម ហើយវិស័យឯកជន ដូចជាគ្រឹះស្ថានហិរញ្ញវត្ថុ និង ធនាគារ និង ក្រុមហ៊ុនធានារ៉ាប់រង ជាដើម អាចធ្វើការងារ

ប្រទាក់ក្រឡាជាមួយគ្នា និង ជាមួយវិស័យសាធារណៈបាន ឱ្យទៅជាចង្កោមនៃអង្គតែមួយនៅក្នុងប្រព័ន្ធអេឡិចត្រូនិចសម្រាប់ធុរកិច្ច តាមរយៈថ្នាល CamDX ។

ជានីតិវិធីនៅក្នុងដំណាក់កាលសាកល្បងនេះ ដើម្បីប្រើប្រាស់ e-KYB APIs, ស្ថាប័នឯកជនដែលបានចូលជាសមាជិកនៃថ្នាល CamDX ត្រូវស្នើសុំបន្ថែមការប្រើប្រាស់ e-KYB APIs មកកាន់មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (ម.ធ.ត.) ដែលជាប្រតិបត្តិករនៃថ្នាល CamDX តាមរយៈប្រព័ន្ធដាក់ពាក្យស្នើសុំចូលជាសមាជិកថ្នាល CamDX។ រីឯ ស្ថាប័នឯកជនដែលមិនមែនជាសមាជិកនៃថ្នាល CamDX និង មានបំណងប្រើប្រាស់ប្រព័ន្ធ e-KYB ត្រូវចូលជាសមាជិកនៃថ្នាល CamDX ជាមុនសិន ទើបទទួលបានការអនុញ្ញាតលើការប្រើប្រាស់ e-KYB APIs ។

គួរបញ្ជាក់ថា លក្ខណៈពិសេសរបស់ប្រព័ន្ធ e-KYB រួមមាន ៖

- ការផ្ទៀងផ្ទាត់បែបឌីជីថល ប្រកបដោយទំនុកចិត្ត និង សុវត្ថិភាព ដោយទិន្នន័យរបស់សហគ្រាសត្រូវបានផ្ទៀងផ្ទាត់ជាមួយនឹងទិន្នន័យគោល (Base Registry) នៃក្រសួង ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល
- ការកំណត់អត្តសញ្ញាណសហគ្រាសក្នុងទម្រង់អេឡិចត្រូនិក ជាមួយនឹងយន្តការផ្ទៀងផ្ទាត់ស្វ័យប្រវត្តិ និង រហ័ស
- យន្តការផ្ទៀងផ្ទាត់ព័ត៌មានច្បាស់លាស់ តាមរយៈការផ្លាស់ប្តូរទិន្នន័យរវាងគ្នា និង គ្នា
- ការចែករំលែកការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និង
- ការប្រើប្រាស់ទិន្នន័យគោល ប្រកបដោយប្រសិទ្ធភាព និង មាននិរន្តរភាពជាងមុន។

សមិទ្ធផលរួមនេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែង និង ការចូលរួមសហការយ៉ាងសកម្មពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល រួមនឹងការផ្តល់មតិយោបល់ដើម្បីស្តាបនាពីវិស័យឯកជន ជាពិសេសក្រោមការគាំទ្រយ៉ាងមុតមាំ និង មគ្គុទេសក៍ដឹកនាំដ៏ឆ្នើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា ជាមួយនឹងការបន្តយកចិត្តទុកដាក់ និង ជួយជ្រោមជ្រែងដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។